៣៥-លោក យឹម - ឃន	មន្ត្រីសាលាស្រុកពញាឮ
៣៦-លោក សាយ- សុខ	មន្ត្រីសាលាស្រុកពញាឮ
៣៧-លោក ពេជ- សុជាតិ	មន្ត្រីជំនួយការការិយាល័យវប្បធម៌ស្រុកពញាឮ
៣៨-លោក សាំង- សាត	អនុប្រធានការិយាល័យសង្គមកិច្ចសាលាស្រុកពញាឮ
៣៩-លោក មៀច- ហឿន	អនុប្រធានការិយាល័យបរិស្ថានស្រុកពញាឮ
៤០-លោក ហេង - គឹមសាន	មន្ត្រីការិយាល័យស្ថិតិផែនការស្រុកពញាឮ
៤១-លោក គង់ - ស៊ុនលី	នគរបាលស្រុកពញាឮ
៤២-លោកស្រី សេង- សីរីមិន	ប្រធានមណ្ឌលសុខភាពឃុំ ភ្នំបាត

គ-មេដាយសំរិទ្ធការងារ :

១-លោក ជ័រ - ពៅ	ប្រធានការិយាល័យស្ថិតិផែនការស្រុកពញ្ញាឮ
២-លោក ស៊ុំ - ឡុង	យោធាស្រុកពញ្ញាឮ
៣-កញ្ញា ចេង ស៊ីផេន	ស្មៀនសាលាស្រុកពញ្ញាឮ
៤-លោក ព្រុំ - វិទូ	អនុប្រធានការិយាល័យសុរិយោដី និង ភូមិបាលស្រុកពញ្ញាឮ
៥-លោក កង - សារ៉ន	មន្ត្រីពន្ធដារស្រុកពញ្ញាឮ
៦-លោក ទឹម - តុន	មន្ត្រីការិយាល័យវប្បធម៌ស្រុកពញ្ញាឮ
៧-លោក ឃុត- ភាព	មន្ត្រីការិយាល័យបរិស្ថានស្រុកពញ្ញាឮ
៨-លោក ផាន់- ភឿន	មន្ត្រីការិយាល័យវប្បធម៌ស្រុកពញ្ញាឮ
៩-លោក នុត - សុធី	មន្ត្រីការិយាល័យស្ថិតិផែនការស្រុកពញ្ញាឮ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង អភិបាលខេត្តកណ្តាល ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ , ថ្ងៃទី ០៦ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧០៥ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយការងារ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួងសាធារណការ និង ដឹកជញ្ជូន

សម្រេច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយការងារ** តាមលំដាប់ថ្នាក់ ជូនមន្ត្រី រាជការ ក្រោមឱវាទក្រសួងសាធារណការ និង ដឹកជញ្ជូន ចំនួន ៥៦រូប ដែលមានស្នាដៃល្អ ក្នុងការបំពេញភារកិច្ចស្តាបនាផ្លូវ ចំនួន ០៣ខ្សែ នៅភាគខាងកើតទន្លេមេគង្គ ក្នុងស្រុកខ្សាច់កណ្តាល ខេត្តកណ្តាល និង ស្ពានបេដ្ឋារចនាសម្ព័ន្ធ ផ្សេងៗ ក្នុងខេត្តកណ្តាល ដូចមានរាយនាមខាងក្រោម :-

ក-មេដាយមាសការងារ :

១-លោក	យ៉ិន	ម៉ិន្តណា	នាយកមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស
២-លោក	តី	សុផាត់	នាយករងមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស
៣-លោក	គួន	ម៉ិនឡឿន	នាយករងមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស
៤-លោក	ជួរ	ឈុនឡេង	អនុប្រធានមន្ទីរ សាធារណការ និង ដឹកជញ្ជូន ខេត្តកណ្តាល

ខ-មេដាយប្រាក់ការងារ :

១-លោក	ឃុន	សុត	ប្រធានការិយាល័យ នៃមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស
២-លោក	ចាន់	ធុន្ធីរ៉ា	អនុប្រធានការិយាល័យ នៃមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស
៣-លោក	នូ	រ័ត្ន	អនុប្រធានការិយាល័យ នៃមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេស
៤-លោក	គីម	ទេត	ប្រធានអង្គភាពស្ពាន-ថ្នល់ មន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តកណ្តាល
៥-លោក	ម៉ម	ម៉ិច	អនុប្រធានអង្គភាពស្ពាន-ថ្នល់ មន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តកណ្តាល
៦-លោក	ទី	គីមសិន	អនុប្រធានអង្គភាពស្ពាន-ថ្នល់ មន្ទីរសាធារណការនិងដឹកជញ្ជូន ខេត្តកណ្តាល
៧-លោក	ស្រែង	សុខ	អនុប្រធានការិយាល័យដឹកជញ្ជូន មន្ទីរសាធារណការ និងដឹកជញ្ជូន ខេត្តកណ្តាល

គ-មេដាយសំរឹទ្ធការងារ :

១-លោក ហេង សែន មន្ត្រីការិយាល័យ សាធារណការ ខេត្តកណ្តាល
២-លោក លី ឈាងស្រេង ប្រធានការិយាល័យ សាធារណការ ស្រុកខ្សាច់កណ្តាល
៣-លោក ហ៊ឹម ច្រឹក មន្ត្រីការិយាល័យ សាធារណការ ខេត្តកណ្តាល
៤-លោក ថៃ ម៉ុល មន្ត្រីការិយាល័យ សាធារណការ ខេត្តកណ្តាល
៥-លោក ឈៀក ខេមរា មន្ត្រីការិយាល័យ សាធារណការ ខេត្តកណ្តាល
៦-លោក អេង រស់ មន្ត្រីការិយាល័យ សាធារណការ ខេត្តកណ្តាល
៧-លោក ម៉ឹម សុពុទ្ធី មន្ត្រីការិយាល័យ សាធារណការ ខេត្តកណ្តាល
៨-លោក ច្រួយ មឿងទ្រាន មន្ត្រីការិយាល័យ សាធារណការ ខេត្តកណ្តាល
៩-លោក ឆេង មាន មន្ត្រី អង្គភាព ស្ពាន-ថ្នល់ ខេត្តកណ្តាល
១០-លោក ប្រាក់ សារិន មន្ត្រី អង្គភាព ស្ពាន-ថ្នល់ ខេត្តកណ្តាល
១១-លោក អ៊ី សឿន មន្ត្រី អង្គភាព ស្ពាន-ថ្នល់ ខេត្តកណ្តាល
១២-លោក ឆេព សុខា បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
១៣-លោក យឹម ភឿន បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
១៤-លោក យឹម សុផល បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
១៥-លោក ខៀវ ចណ្ណា បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
១៦-លោក សាក់ ចន្ថា បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
១៧-លោក ជា ឈារិន បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
១៨-លោក ហាច់ ឈួន បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
១៩-លោក យឹម សារុន បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
២០-លោក ធន សុខចាន់ បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
២១-លោក ម៉ោង ស៊ា បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
២២-លោក ជុំ ខិន បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
២៣-លោក សុន សន បុគ្គលិកបើកបរគ្រឿងចក្រ អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
២៤-លោក អោយ ខួន បុគ្គលិកជួសជុលម៉ាស៊ីន អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
២៥-លោក ហេង ខួន បុគ្គលិកជួសជុលម៉ាស៊ីន អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
២៦-លោក យឹម យឿន បុគ្គលិកជួសជុលម៉ាស៊ីន អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
២៧-លោក ជា សារ៉ាន់ បុគ្គលិកជួសជុលម៉ាស៊ីន អង្គភាពស្ពាន-ថ្នល់ ខេត្តកណ្តាល
២៨-លោក ឡុល សារិន អនុប្រធានការិយាល័យរដ្ឋបាលបុគ្គលិក មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តកណ្តាល
២៩-លោក សោម សារ៉េត អនុប្រធានការិយាល័យរដ្ឋបាលបុគ្គលិក មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តកណ្តាល
៣០-លោក អ៊ុក ដី អនុប្រធានការិយាល័យ ផែនការគណនេយ្យ មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តកណ្តាល
៣១-លោក ហ៊ុល ចំរើន អនុប្រធានការិយាល័យ ផែនការគណនេយ្យ មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តកណ្តាល
៣២-លោកស្រី សៀន សាមគ្គី មន្ត្រីការិយាល័យ ផែនការគណនេយ្យ មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តកណ្តាល

៣៣-កញ្ញា ស្នួន សារម៉ឿន មន្ត្រីការិយាល័យ សាធារណការ ខេត្តកណ្តាល
៣៤-លោក ឡូច សារ៉ែត ក្រុមអាជីវកម្ម ដីកដី
៣៥-លោក ម៉ឿន រ៉ន ក្រុមអាជីវកម្ម ដីកដី
៣៦-លោក ហោច ឡេង ក្រុមអាជីវកម្ម ដីកដី
៣៧-លោក ហ៊ីន សុផា ក្រុមអាជីវកម្ម ដីកដី
៣៨-លោក ហួរ ឡុង ក្រុមអាជីវកម្ម ដីកដី
៣៩-លោក ឈុក កែ ក្រុមអាជីវកម្ម ដីកដី
៤០-លោក ឡា ម៉េង អ្នកជួយឧបត្ថម្ភសំភារៈសំណង់
៤១-លោក ម៉ែម សំអុន មន្ត្រីការិយាល័យ សាធារណការ ខេត្តកណ្តាល
៤២-លោក ម៉ាច់ សុផុន មន្ត្រីការិយាល័យ សាធារណការ ខេត្តកណ្តាល
៤៣-លោក ជា សារុន អនុប្រធានការិយាល័យ សាធារណការ ស្រុកតាខ្មៅ
៤៤-លោក សេក សាន អនុប្រធានការិយាល័យ សាធារណការ ស្រុកតាខ្មៅ
៤៥-លោក ហោច ម៉េងហ៊ី មន្ត្រីការិយាល័យ ផែនការគណនេយ្យ មន្ទីរសាធារណការ និង ដឹកជញ្ជូន ខេត្តកណ្តាល

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង រដ្ឋមន្ត្រី ក្រសួងសាធារណការ និង ដឹកជញ្ជូន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ.ថ្ងៃទី ០៧ ខែ ៤ ឆ្នាំ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

02-204

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤០៦ អនក្រ.តត

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

សំរេច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយស្ថាបនាជាតិ** តាមលំដាប់ថ្នាក់ ជូនសប្បុរសជនចំនួន ០៩ រូប ដែលបានបរិច្ចាគធនធាន ជួយកសាងសមិទ្ធផលផ្សេងៗ ក្នុងវត្តព្រៃឈើទាល ឃុំធ្លក ស្រុកទ្រាំង ខេត្តតាកែវ ដូចមានរាយនាមខាងក្រោម ÷

ក-មេដាយមាសស្ថាបនាជាតិ :

១-លោកយាយ **ទ័ត លេន** នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ១២.០០០ ដុល្លារ

២-លោក **ហ៊ិន គិន** អ្នកស្រី **ជួន អ៊ឹម** នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ១០.៥០០ ដុល្លារ

៣-លោកស្រី **ប្រាក់ គឹមស៊ា** នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ១០.០៥០ ដុល្លារ

ខ-មេដាយសំរឹទ្ធស្ថាបនាជាតិ :

១-លោកស្រី **ម៉ារី សោ** នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ២.៧៤០ ដុល្លារ

២-លោកគ្រូ **ម៉ម សាម៉ន** នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ២.៥០០ ដុល្លារ

៣-លោកស្រី **ស៊ឹម វ៉ុន** នៅប្រទេសអូស្ត្រាលី ទឹកប្រាក់ចំនួន ២.១៥០ ដុល្លារ

៤-លោកយាយ **ជូ ណែលហ៊ីម** នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ២.០០០ ដុល្លារ

៥-លោកតា **ឡុង** និងលោកយាយ **ជួន** នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ២.០០០ ដុល្លារ

៦-លោកយាយ **ម៉េត សេន** នៅសហរដ្ឋអាមេរិក ទឹកប្រាក់ចំនួន ១.៩៥០ ដុល្លារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និង អភិបាលខេត្តតាកែវ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

រាជធានីភ្នំពេញ , ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: [illegible]

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូន Mr. JUNG DOO JIN Ph.D Daigu Polytechnic College in Korea ដែលបានធ្វើអំណោយម៉ាស៊ីនកុំព្យូទ័រចំនួន ០៩ គ្រឿង ជូនដល់ទីចាត់ការបុគ្គលិកនៃអគ្គបញ្ជាការដ្ឋាន កងយោធពលខេមរភូមិន្ទ មានតម្លៃជាទឹកប្រាក់ចំនួន ៨.០០០ ដុល្លារ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ខែ [illegible] ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០៨. អនក្រ.តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា១ : តែងតាំងលោក **នុច នីន** ចុះឈ្មោះអគ្គាធិការរងនៃអគ្គាធិការដ្ឋាន នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាប្រធាននាយកដ្ឋានរដ្ឋបាល ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី, រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ២០៩ . អនក្រ . តត

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា១ : តែងតាំងលោក **អេង ហ៊ីន** បច្ចុប្បន្នប្រធាននាយកដ្ឋានរដ្ឋបាល នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាប្រធាននាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ⁄ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ៤១០. អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា១ : តែងតាំងលោក **ហែម ហេង** បច្ចុប្បន្នប្រធាននាយកដ្ឋានអាស៊ីទី២ នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាប្រធាននាយកដ្ឋានពត៌មាន និងឯកសារ ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ២
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ២១១ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១០ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ០៤០១ / ០៨៥ ចុះថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០០១ ស្តីពីលក្ខន្តិកៈដោយឡែក នៃក្របខ័ណ្ឌមន្ត្រីការទូតជាន់ខ្ពស់
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ

សំរេច

មាត្រា១ : តែងតាំងលោក **ស៊ីន សួន** បច្ចុប្បន្នប្រធាននាយកដ្ឋានអាមេរិក នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ជាប្រធាននាយកដ្ឋានអាស៊ីទី២។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ⁄ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នដែលពាក់ព័ន្ធ និង សាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៧ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល:
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ-កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា **ជាតិ សាសនា ព្រះមហាក្សត្រ**

លេខៈ ២១២ អនក្រ.តត

អនុក្រឹត្យ

ស្តីពី

ការតែងតាំងមន្ត្រីរាជការ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២៩៩/២២០ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតរាជបណ្ឌិតសភាកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រាជបណ្ឌិតសភាកម្ពុជា
- យោងតាមសំណើរបស់ប្រធានរាជបណ្ឌិតសភាកម្ពុជា

សំរេច

មាត្រា១ : ត្រូវបានតែងតាំងមន្ត្រីរាជការ នៃរាជបណ្ឌិតសភាកម្ពុជា ចំនួន០៤រូប ដូចមានរាយនាមខាងក្រោម÷

១- លោក **ហ៊ីម សុភី** ជាប្រធានផ្នែកសិល្បៈប្រជាប្រិយ នៃវិទ្យាស្ថានវប្បធម៌ និងវិចិត្រសិល្បៈ មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

២- លោក **ទុំ ម៉ុង** ជាប្រធានផ្នែកទស្សនវិជ្ជា និងសង្គមវិជ្ជា នៃវិទ្យាស្ថានមនុស្សសាស្ត្រ និងវិទ្យាសាស្ត្រសង្គម មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

៣- លោក **ចាន់ ថុន្នី** ជាលេខាអចិន្ត្រៃយ៍ នៃវិទ្យាស្ថានជីវសាស្ត្រ វេជ្ជសាស្ត្រ និងកសិកម្ម មានឋានៈស្មើ **ប្រធាននាយកដ្ឋាន** ។

៤- លោក **សន ពៅ** ជាលេខាអចិន្ត្រៃយ៍ នៃវិទ្យាស្ថានភាសាជាតិ មានឋានៈស្មើ **ប្រធាន-នាយកដ្ឋាន** ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រធានរាជបណ្ឌិត-សភាកម្ពុជា រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ សហរដ្ឋមន្ត្រី រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង-ស្ថាប័នដែលពាក់ព័ន្ធ និងសាមីខ្លួន ត្រូវអនុវត្តអនុក្រឹត្យនេះឱ្យមាន-ប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី[illegible] ខែមេសា ឆ្នាំ២០០៤

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤២ អនក្រ.បក

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ នៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រឹត្យលេខ ជស/រកត/១០៩៥/០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និង ប្រើប្រាស់គ្រឿងឥស្សរិយយស នៃ ព្រះរាជាណាចក្រកម្ពុជា

-តាមសំណើរបស់ រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា

ស ំ រ េ ច

មាត្រា១ : ត្រូវបានបំពាក់ **មេដាយមាសស្ថាបនាជាតិ** ចំនួន ០៣ គ្រឿង ប្រគេនព្រះសង្ឃ ចំនួន ០៣ អង្គ ដែលបានយកព្រះទ័យទុកដាក់ ក្នុងការបំផុសចលនាពុទ្ធបរិស័ទ និងបានបរិច្ចាគបច្ច័យផ្ទាល់ព្រះអង្គ ចូលរួមជួយកសាង កុដិ ក្លោងទ្វារចូលវត្ត និង សមិទ្ធផលមួយចំនួនទៀត នៅវត្តញាណរង្សី សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ វត្តគោកបញ្ជាន់ សង្កាត់ចោមចៅ ខណ្ឌដង្កោ និងវត្តព្រះពុទ្ធឃោសាចារ្យ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ដូចមាននាមព្រះនាមខាងក្រោមនេះ :-

១-ព្រះតេជគុណព្រះមង្គលរក្ខិត **ទឹម សម្បត្តិ** ព្រះរាជាគណៈថ្នាក់កិត្តិយស ទីប្រឹក្សាផ្ទាល់សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និង ជាព្រះចៅអធិការ វត្តញាណរង្សី បច្ច័យចំនួន ១៤.០៩០ ដុល្លារអាមេរិក ។

២-ព្រះតេជគុណ ព្រះវិសាលបញ្ញោ **សេខ ឡេខ** ព្រះរាជាគណៈថ្នាក់កិត្តិយស ទីប្រឹក្សាផ្ទាល់សម្តេចព្រះសង្ឃរាជគណៈមហានិកាយ និង ជាព្រះចៅអធិការ វត្តគោកបញ្ជាន់ បច្ច័យចំនួន ២៥.៩៦០ ដុល្លារអាមេរិក ។

៣-ព្រះតេជគុណព្រះគ្រូវិសុទ្ធសីលាចារ្យ **ជឹម ខេវេន** ព្រះគ្រូសូត្រស្តាំ វត្តព្រះពុទ្ធឃោសាចារ្យ បច្ច័យចំនួន ១៨.៥៧០ ដុល្លារអាមេរិក ។

មាត្រា២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួង ធម្មការ និង សាសនា និង អភិបាលរាជធានីភ្នំពេញ ត្រូវអនុវត្ត អនុក្រឹត្យ នេះ អោយទទួលបានលទ្ធផលល្អ ។/៚

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និងមាត្រា២
-រាជកិច្ច
-ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧១៤ អនក្រ.តត

អនុក្រឹត្យ
ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
-បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
-បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
-តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ំ រេ ច

មាត្រា ១ :ត្រូវបានបំពាក់ **មេដាយគ្រាក់ស្ថាបនាជាតិ** ជូនសប្បុរសជនកូរ៉េចំនួន ០៣ រូប ដែលបានជួយឧបត្ថម្ភសម្ភារៈ ជូនកងយោធពលខេមរភូមិន្ទ រួមមានកុំព្យូទ័រចំនួន ៥០ គ្រឿង សំលៀកបំពាក់ចំនួន ៦០០ សំរាប់ និង ស្បែកជើងចំនួន ២៥០ គូ មានតម្លៃជាទឹកប្រាក់ចំនួន ២៧.២៥០ ដុល្លារ ដូចមានរាយនាមខាងក្រោម ÷

១-Mrs. LEE KEUMJA Chairwomen Kyonggi-do Womens Group Association ទឹកប្រាក់ចំនួន ៩.០៨៣.៣ ដុល្លារ

២-Mr. PARK YOUNGHO Ceo Koecotech Co.Ltd ទឹកប្រាក់ចំនួន ៩.០៨៣.៣ ដុល្លារ

៣-Dr. JIN BANGHO Chairman of Korea Invention Group Association ទឹកប្រាក់ចំនួន ៩.០៨៣.៣ ដុល្លារ

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ

រាជធានីភ្នំពេញ . ថ្ងៃទី០៩ ខែមេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :
-ក្រសួងព្រះបរមរាជវាំង
-អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
-អគ្គលេខាធិការដ្ឋានរដ្ឋសភា
-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
-ដូចក្នុងមាត្រា១ និង មាត្រា២
-រាជកិច្ច
-ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៥១៥ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការជូនមេដាយស្ថាបនាជាតិ

&&&&&

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត /១១៩៨ /៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ /នស /៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ ជស /រកត /១០៩៥ /០១ ចុះថ្ងៃទី ០៥ ខែ តុលា ឆ្នាំ ១៩៩៥ ស្តីពីការបង្កើត និងប្រើប្រាស់គ្រឿងឥស្សរិយយស នៃព្រះរាជាណាចក្រកម្ពុជា
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងការពារជាតិ

ស ម្រេ ច

មាត្រា ១ : ត្រូវបានបំពាក់ **មេដាយថ្នាក់ស្ថាបនាជាតិ** ជូនលោក LEE EUNG SOO នាយផ្នែកចាត់ការក្រុមហ៊ុនកូរ៉េ ដែលបានផ្តល់ថវិកាចំនួន ៦.៩៥០ ដុល្លារ សំរាប់ជួយឧបត្ថម្ភដល់វគ្គហ្វឹកហ្វឺនបណ្តុះបណ្តាល SCUBA កងទ័ពជើងទឹកជំនាន់ទី ២ ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និង សហរដ្ឋមន្ត្រីក្រសួងការពារជាតិ ត្រូវអនុវត្តអនុក្រឹត្យនេះ អោយទទួលបានលទ្ធផលល្អ ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចក្នុងមាត្រា១ និង មាត្រា២
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ: ៤១៦ អនក្រ.បក

អនុក្រឹត្យ

ស្តីពីការតែងតាំងមន្ត្រីរាជការ

* * *

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ ០២ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មករា ឆ្នាំ ១៩៩៩ ស្តីពីការបង្កើតអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- បានឃើញអនុក្រឹត្យលេខ ៣០ អនក្រ.បក ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍
- យោងតាមសំណើរបស់អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍

សំរេច

មាត្រា ១ : ត្រូវបានតែងតាំងលោក **តែង គន្ធី** ជាអគ្គលេខាធិការរង នៃអាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ មានឋានៈស្មើ **អគ្គនាយករង** ។

មាត្រា ២ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី អាជ្ញាធរជាតិប្រយុទ្ធនឹងជំងឺអេដស៍ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួងស្ថាប័នពាក់ព័ន្ធ និងសាមីខ្លួនត្រូវអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចមាត្រា ២*
- *ឯកសារ_កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខ: ១៥ អនក្រ

សេចក្តីសំរេច
ស្តីពី
ការតែងតាំងសមាជិកគណៈកម្មាធិការគ្រប់គ្រង អាកាសយានដ្ឋានអន្តរជាតិ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២៣ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ១៣ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
- បានឃើញអនុក្រឹត្យលេខ ៦៤ អនក្រ.បក ចុះថ្ងៃទី ០៩ ខែ កក្កដា ឆ្នាំ ២០០១ ស្តីពីការកំណត់ និងការគ្រប់គ្រងទីស្នាក់ការត្រួតពិនិត្យច្រកទ្វារអន្តរជាតិ ច្រកទ្វារព្រំដែនអន្តរជាតិ ច្រកទ្វារព្រំដែនទ្វេភាគី ច្រកទ្វារតំបន់ព្រំដែន និងច្រកទ្វារកំពង់ផែសមុទ្រ នៅទូទាំងព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មីនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋាន អន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា

សម្រេច

ប្រការ ១.-

ត្រូវបានតែងតាំងជាសមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដែលមានសមាសភាព ដូចខាងក្រោម :

- ឯកឧត្តម **សុខ អាន** ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធាន
- ឯកឧត្តម **ព្រុំ សុខា** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តម នាយឧត្តមសេនីយ៍ **ហុក ឡុងឌី** អគ្គស្នងការ នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ អនុប្រធាន
- ឯកឧត្តម នាយឧត្តមសេនីយ៍ **ម៉ុល សារឿន** អគ្គមេបញ្ជាការរង នៃអគ្គបញ្ជាការដ្ឋានកងយោធពលខេមរភូមិន្ទ អនុប្រធាន
- ឯកឧត្តម **កែវ សាផល** អនុរដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល អនុប្រធានប្រចាំការ
- ឯកឧត្តម **ដាន់ ទួន** អនុរដ្ឋលេខាធិការ ក្រសួងការពារជាតិ សមាជិក
- ឯកឧត្តម **ឡុង វិសាលោ** អនុរដ្ឋលេខាធិការ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ សមាជិក
- ឯកឧត្តម **ពៅ សាមី** អគ្គលេខាធិការនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក
- ឯកឧត្តម **ជា សុខុម** អគ្គលេខាធិការរងទី១នៃអគ្គលេខាធិការដ្ឋានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ-អន្តរជាតិ សមាជិក
- ឯកឧត្តមឧត្តមសេនីយ៍ឯក **សៅ សុខា** មេបញ្ជាការកងរាជអាវុធហត្ថលើផ្ទៃប្រទេស សមាជិក
- ឯកឧត្តម **ញាណ ឡេង** អនុរដ្ឋលេខាធិការ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **មាស គីមសុវ៉ារ៉ូ** អនុរដ្ឋលេខាធិការ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- ឯកឧត្តមឧត្តមសេនីយ៍ទោ **ស៊ឹង សំណាង** មេបញ្ជាការកងទ័ពជើងអាកាស សមាជិក
- ឯកឧត្តម **គ្រាញ់ តូនី** សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក
- ឯកឧត្តម **កែប ជុតិមា** អភិបាលរាជធានីភ្នំពេញ សមាជិក
- ឯកឧត្តម **អ៊ុង អឿន** អភិបាលរងទី១ខេត្តសៀមរាប សមាជិក

២

- ឯកឧត្តម **ម៉ែន ស៊ីម៉ន** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកទីចាត់ការគយ និងរដ្ឋាករ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- ឯកឧត្តម **សូ ម៉ារ៉ា** អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ សមាជិក
- លោក **ស៊ុត សារា** ប្រធាននាយកដ្ឋានកាំកុងត្រូល ក្រសួងពាណិជ្ជកម្ម សមាជិក
- លោក **ម៉ុន នី** ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និងជាប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ សមាជិក
- លោក **ម៉ុន រដ្ឋា** ប្រធានក្រុមប្រតិបត្តិការសន្តិសុខអាកាសយានដ្ឋានអន្តរជាតិសៀមរាប និងជាប្រធានក្រុមត្រួតពិនិត្យច្រកទ្វារអាកាសយានដ្ឋានអន្តរជាតិសៀមរាប សមាជិក

ប្រការ ២.-

សមាជិកគណៈកម្មាធិការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ ដូចមានចែងក្នុងប្រការ១ នៃសេចក្តីសំរេចនេះ មានភារកិច្ចអនុវត្តការងារស្របតាមខ្លឹមសារ និងបទប្បញ្ញត្តិ ដូចមានចែងក្នុងអនុក្រឹត្យលេខ ០៦ អនក្រ.បក ចុះថ្ងៃទី ៣០ ខែ មិនា ឆ្នាំ ២០០៤ ស្តីពីការគ្រប់គ្រងអាកាសយានដ្ឋានអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា ។

ប្រការ ៣.-

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ សហរដ្ឋមន្ត្រីក្រសួងការពារជាតិ រដ្ឋមន្ត្រីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋលេខាធិការនៃរដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល រដ្ឋមន្ត្រី រដ្ឋលេខាធិការ នៃក្រសួង ស្ថាប័ន អភិបាលខេត្ត-ក្រុងពាក់ព័ន្ធ និងក្រុមហ៊ុនសម្បទានអាកាសយានដ្ឋានអន្តរជាតិ ព្រមទាំងសាមីខ្លួន ដូចមានចែង ក្នុងប្រការ១ ត្រូវទទួលអនុវត្តសេចក្តីសំរេចនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញ ថ្ងៃទី [illegible] ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ១៦ សសរ

សេចក្តីសំរេច
ស្តីពី
ការបន្ថែមភារៈកិច្ច និងសមាជិកគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវបានខ្ចីយកទៅតាំងពិពណ៌ នៅប្រទេសជប៉ុន សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និងសាធារណរដ្ឋកូរ៉េ

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ លេខ នស /រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម លេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការបង្កើតទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើត ក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០២ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ
- បានឃើញសេចក្តីសំរេចស្តីពីការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យលើវត្ថុបុរាណសិល្បៈខ្មែរ លេខ ០៥ ស.ស.រ. ចុះថ្ងៃទី ០៦ ខែកុម្ភៈ ឆ្នាំ ២០០៤
- យោងតាមតម្រូវការចាំបាច់ នៃការងារ

សំរេច

ប្រការ ១: គណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលមានភារៈកិច្ចដូច ដែលបានកំណត់ដោយសេចក្តីសំរេច លេខ ០៥ ស.ស.រ. ចុះថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០០៤ ត្រូវទទួលភារៈកិច្ចបន្ថែមលើការងារបច្ចុប្បន្ន ក្នុងការសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលក្រុមហ៊ុន CNK Bridge Company Co., Ltd. សាធារណរដ្ឋកូរ៉េ ខ្ចីយកទៅតាំងពិពណ៌នៅសាធារណរដ្ឋកូរ៉េ ពីថ្ងៃទី ២៨ ខែ មិថុនា ដល់ថ្ងៃទី ៣០ ខែ សីហា ឆ្នាំ ២០០៤។

ប្រការ ២: ត្រូវបានបន្ថែមសមាជិក ចំនួន ២ រូប ទៀតក្នុងគណៈកម្មការអន្តរក្រសួងដើម្បីសម្របសម្រួល វាយតម្លៃ និងត្រួតពិនិត្យ លើវត្ថុបុរាណសិល្បៈខ្មែរ ដែលត្រូវបានខ្ចីយកទៅតាំងពិពណ៌នៅប្រទេសជប៉ុន សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ និង សាធារណរដ្ឋកូរ៉េ ដែលមានសមាសភាពដូចខាងក្រោម :

១- លោក **សួស យ៉ារ៉ា**	តំណាងអាជ្ញាធរជាតិទេសចរណ៍កម្ពុជា	សមាជិក
២- លោក **ឡាយ ឈារិទ្ធ**	អនុប្រធាននាយកដ្ឋានស្ថាបនា ក្រសួងមហាផ្ទៃ	សមាជិក

ប្រការ ៣: រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងវប្បធម៌និងវិចិត្រសិល្បៈ រដ្ឋមន្ត្រីក្រសួងទេសចរណ៍ រដ្ឋមន្ត្រីក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អាជ្ញាធរអប្សរា ប្រធាន អនុប្រធាន និងសមាជិកគណៈកម្មការ ដែលបានរាយនាមក្នុង ប្រការ ២ ត្រូវអនុវត្តសេចក្តីសំរេចនេះ អោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ០៩ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៣
- ឯកសារ-កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៧ សសរ

សេចក្តីសំរេច

ស្តីពី

ការបង្កើតគណៈកម្មការអន្តរក្រសួង
ដើម្បីស្រាវជ្រាវការផ្លាស់ប្តូរចំណតរថយន្ត នៅច្រកទ្វារព្រំដែនទេពាគីត្រពាំងផ្លុង ខេត្តកំពង់ចាម

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីស្រាវជ្រាវការផ្លាស់ប្តូរចំណតរថយន្ត នៅច្រកទ្វារព្រំដែនទេពាគីត្រពាំងផ្លុង ខេត្តកំពង់ចាម ដែលមានសមាសភាពដូចខាងក្រោម :

១-ឯកឧត្តម ប៉ុល លឹម	អគ្គាធិការរង នៃអគ្គាធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល និងនគរបាល ក្រសួងមហាផ្ទៃ	ប្រធាន
២-លោក ហួរ ផល្លា	អនុប្រធានអធិការដ្ឋានកិច្ចការនយោបាយ រដ្ឋបាល ក្រសួងមហាផ្ទៃ	សមាជិក
៣-លោក អៀម ចយ	អនុប្រធាននាយកដ្ឋានរដ្ឋបាលទូទៅ ក្រសួងមហាផ្ទៃ	សមាជិក
៤-លោក គឹម ប៊ី	នាយករងមជ្ឈមណ្ឌលស្រាវជ្រាវបច្ចេកទេសសាធារណការ នៃក្រសួងសាធារណការ និងដឹកជញ្ជូន	សមាជិក

៥-លោក សុខ ស្រ៊ុន	នាយករងមន្ទីរសាធារណការ ដឹកជញ្ជូន ខេត្តកំពង់ចាម	សមាជិក
៦-លោក ឃឹម សួរ	អនុប្រធានការិយាល័យចំណូលសាធារណៈ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ចស្រាវជ្រាវ អំពីការលើកផ្លាស់ប្តូរទីតាំងចំណតផែបន្ទុកទៅក្រោមទ្វារព្រំដែនទ្វេភាគីត្រពាំងផ្លុង ខេត្តកំពង់ចាម រួចហើយលើកយោបល់ជូនប្រមុខរាជរដ្ឋាភិបាលសំរេច ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន អាជ្ញាធរខេត្តកំពង់ចាម និងឯកឧត្តម អស់លោក ដូចមានចែងក្នុងប្រការ១ មានភារកិច្ចអនុវត្តសេចក្តីសំរេចនេះ ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ,ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៤

ជ. នាយករដ្ឋមន្ត្រី
ឧបនាយករដ្ឋមន្ត្រី

ស ខេង

កន្លែងទទួល :
- *ទីស្តីការគណៈរដ្ឋមន្ត្រី*
- *ក្រសួងសេដ្ឋកិច្ច និងដឹកជញ្ជូន*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី* ✓
- *ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី ស ខេង*
- *សាលាខេត្តកំពង់ចាម*
- *ឯកសារ កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ :១៨ សសរ

សេចក្តីសំរេច

ស្តីពី

ការបង្កើតគណៈកម្មការទទួលបន្ទុករៀបចំបុណ្យសព ឯកឧត្តម តុល ឡោះ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជននិងកីឡា

- យោងតាមសេចក្តីជូនដំណឹងរបស់គណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ- អន្តរជាតិ
- យោងតាមសំណូមពរ និងការងារចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : ត្រូវបានបង្កើតគណៈកម្មការ ដើម្បីរៀបចំបុណ្យសពឯកឧត្តម តុល ឡោះ ដែលមានសមាសភាពដូចខាងក្រោម ÷

១-	ឯកឧត្តម	អ៊ឹម	សិទ្ធី	សហប្រធាន
២-	ឯកឧត្តម	ប៉ុក	ថន	សហប្រធាន
៣-	ឯកឧត្តម	ប៊ុន	សុខ	អនុប្រធាន
៤-	ឯកឧត្តម	ហែម	សំកុល	អនុប្រធាន
៥-	ឯកឧត្តម	ឆយ	អួន	សមាជិក
៦-	ឯកឧត្តម	កើ	ណៃលាង	សមាជិក
៧-	លោក	ជា	អៀង	សមាជិក
៨-	លោក	លី	សន្និក	សមាជិក

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

- ទទួលបន្ទុករៀបចំបុណ្យសពឯកឧត្តម តុល ឡោះ ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា អោយបានល្អប្រសើរ ស្របតាមប្រពៃណី សាសនា និងអោយបានសក្តិសមនឹងកិត្តិយសរបស់សព ដោយសហការជាមួយគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ- អន្តរជាតិ ។

- ដោះស្រាយថវិកាសំរាប់បំរើការងាររៀបចំពិធីបុណ្យសព ។
- សមាជិកគណៈកម្មការត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់សហប្រធានគណៈកម្មការ ។

ប្រការ ៣ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋលេខាធិការក្រសួងអប់រំ យុវជន និងកីឡា ប្រធានគណៈកម្មការអចិន្ត្រៃយ៍រៀបចំបុណ្យជាតិ- អន្តរជាតិ រដ្ឋមន្ត្រី រដ្ឋលេខាធិការ គ្រប់ក្រសួង- ស្ថាប័នដែលពាក់ព័ន្ធ សហប្រធានគណៈកម្មការរៀបចំបុណ្យសព ឯកឧត្តម តុល ឡោះ និងសមាសភាពគណៈកម្មការដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តសេចក្តីសំរេចនេះអោយមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ៕

រាជធានីភ្នំពេញ, ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០០៤

ហ៊ុន សែន

<u>ចម្លងជូន</u> :
- *ក្រសួងព្រះបរមរាជវាំង*
- *អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា*
- *អគ្គលេខាធិការដ្ឋានរដ្ឋសភា*
- *ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
- *ដូចប្រការ ៣*
- *ឯកសារ- កាលប្បវត្តិ*

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ១៩ សសរ

សេចក្ដីសម្រេច
ស្ដីពី
ការបង្កើតគណៈកម្មការអន្តរក្រសួង ដើម្បីធ្វើការសិក្សាលើធនធានខ្សាច់សំរាប់នាំចេញ ទៅកាន់ប្រទេសសិង្ហបុរី

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់រាជរដ្ឋាភិបាល

សំរេច

ប្រការ ១ : បង្កើតគណៈកម្មការអន្តរក្រសួងមួយដើម្បីធ្វើការសិក្សាលើធនធានខ្សាច់សំរាប់នាំចេញទៅកាន់ប្រទេសសិង្ហបុរីដែលមាន

សមាសភាព :

១-ឯកឧត្ដម	**សយ សុខា**	អគ្គលេខាធិការក្រុមសង្កេតការណ៍សេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌	ប្រធាន
២-ឯកឧត្ដម	**ម៉ៅ ថូរ៉ា**	អគ្គនាយកបច្ចេកទេស នៃក្រសួងពាណិជ្ជកម្ម	អនុប្រធាន
៣-លោក	**ម៉ី លីហ្វួត**	អគ្គនាយករងកិច្ចការរដ្ឋបាលនៃក្រសួងធនធានទឹក និង ឧតុនិយម	អនុប្រធាន
៤-លោក	**សុខ ឡេង**	ប្រធាននាយកដ្ឋានធនធានរ៉ែ នៃក្រសួងឧស្សាហកម្ម	អនុប្រធាន
៥-លោក	**សៀវ សុថារ**	ប្រធាននាយកដ្ឋានភូគព្ភសាស្ត្រ នៃក្រសួងឧស្សាហកម្ម	សមាជិក

៧-លោក ពត នរារិន	ប្រធាននាយកដ្ឋាន វាយតំលៃ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា	សមាជិក
៨-លោក គាំង លាងខំណុ	ប្រធាននាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនៃក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	សមាជិក
៩-លោក ឆា ជុំប	ប្រធាននាយកដ្ឋានពិនិត្យអង្កេតវាយតំលៃហេតុប៉ះពាល់បរិស្ថាននៃក្រសួងបរិស្ថាន	សមាជិក
១០-លោក ទាវ គីមស៊ីមសុរិយា	ប្រធាននាយកដ្ឋានផែនការ នៃក្រសួងសាធារណៈការ និងដឹកជញ្ជូន	សមាជិក
១១-លោក អេង ជាសាន	អនុប្រធាននាយកដ្ឋានផលផល នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	សមាជិក
១២-លោក ជា វណ្ណដេត	អនុប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ នៃទីស្តីការគណៈរដ្ឋមន្ត្រី	សមាជិក
១៣-លោក ទៅ សុខ៊ាង	ប្រធានផ្នែកកសិកម្ម ឧស្សាហកម្ម និងអភិវឌ្ឍន៍ជនបទ កសសស.	លេខាធិការ
១៤-លោក ខាន់ តិរុណ	មន្ត្រី កសសស.	លេខាធិការ

ប្រការ ២ : គណៈកម្មការនេះមានភារកិច្ច :

-ពិនិត្យជ្រើសរើសទីតាំងសំរាប់ធ្វើការដ្ឋានយកខ្សាច់ និងប្រមូលពត៌មានទាក់ទងដល់អាជីវកម្ម

-កំណត់បរិមាណ និងគុណភាពខ្សាច់ដែលផលិតបានសំរាប់ការផ្គត់ផ្គង់ក្នុងស្រុក និងនាំចេញ

-ស្រាវជ្រាវតំលៃលក់ក្នុងស្រុក និងតំលៃនាំចេញខ្សាច់តាមយថាប្រភេទ

-ពិនិត្យ និងការពារផលប៉ះពាល់បរិស្ថាន ដែលទាក់ទងដល់ការធ្វើអាជីវកម្មខ្សាច់

-ពិនិត្យ ពិភាក្សាលើបញ្ហាបច្ចេកទេស បែបបទ និងនីតិវិធីផ្សេងៗដែលទាក់ទងដល់ការធ្វើអាជីវកម្ម និងការនាំចេញខ្សាច់

-រាយការណ៍អំពីលទ្ធផលចរចាជាមួយគណៈប្រតិភូសិង្ហបុរីអំពីការធ្វើអាជីវកម្មលើការនាំចេញខ្សាច់ជូនរាជរដ្ឋាភិបាលពិនិត្យ និងសំរេច ។

ប្រការ ៣ : អនុប្រធាន សមាជិកគណៈកម្មការត្រូវចូលរួមការប្រជុំតាមការអញ្ជើញរបស់ប្រធានគណៈកម្មការ ។

ប្រការ ៤ : គណៈកម្មការនេះមានសិទ្ធិប្រើប្រាស់ត្រារបស់ទីស្តីការគណៈរដ្ឋមន្ត្រីជាផ្លូវការ ។

ប្រការ ៥ : រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសាធារណៈការ និងដឹកជញ្ជូន រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងសាមីខ្លួនដូចមានចែងក្នុងប្រការ ១ ត្រូវអនុវត្តតាមសេចក្តីសំរេចនេះ អោយ មានប្រសិទ្ធិភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចប្រការ ៥
- ឯកសារ- កាលប្បវត្តិ

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខៈ ០៧ សរ.ណ.ខ

សារលិខិត

របស់រាជរដ្ឋាភិបាលផ្ញើជូនជនរួមជាតិកម្ពុជា

ក្នុងឱកាសបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិ ឆ្នាំ វក ឆស័ក ព.ស ២៥៤៨

- សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ
- សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី
- បងប្អូនជនរួមជាតិ ដែលកំពុងរស់នៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជាទាំងអស់ជាទីមេត្រី

ថ្ងៃ ទី ០៩-១០ និង ១១ រោច ខែ ចេត្រ ឆ្នាំ វក ឆស័ក ព.ស ២៥៤៨ ត្រូវនឹងថ្ងៃអង្គារ ទី ១៣ ថ្ងៃពុធ ទី ១៤ និងថ្ងៃព្រហស្បតិ៍ ទី ១៥ ខែ មេសា ឆ្នាំ ២០០៤ គឺជាទិវាដ៏មហាប្រសើរ ប្រកបដោយសិរីសួស្តី ជ័យមង្គល ដែលប្រជាជាតិខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា រួបរួមគ្នាប្រារព្ធទិវាបុណ្យចូលឆ្នាំខ្មែរប្រពៃណីជាតិលើកទី៦ ក្រោមបរិយាកាសសប្បាយរីករាយ ដែលមាតុភូមិនៃយើងទទួលបានសុខសន្តិភាពពេញលេញលើផ្ទៃប្រទេសទាំងមូល បន្ទាប់ពីការអនុវត្តប្រកបដោយជោគជ័យនូវនយោបាយឈ្នះ ឈ្នះ របស់រាជរដ្ឋាភិបាលកន្លងមក។

ក្នុងរយៈពេលឆ្នាំចាស់ ឆ្នាំមមែ បញ្ចស័ក ព.ស ២៥៤៧ ដែលទើបបញ្ចប់ទៅនេះ រាជរដ្ឋាភិបាលមានមោទនភាពយ៉ាងក្រៃលែង ដោយសំរេចបាននូវលទ្ធផលល្អប្រសើរក្នុងការធានា និងរក្សាបានទាំងស្រុងនូវស្ថិរភាពនយោបាយ កិច្ចការពារសន្តិសុខ សុវត្ថិភាព និងសណ្តាប់ធ្នាប់សាធារណៈ ជូនប្រជាពលរដ្ឋខ្មែរ វិនិយោគិន ភ្ញៀវទេសចរបរទេស អង្គទូត គណបក្សនយោបាយ សមាគម អង្គការក្រៅរដ្ឋាភិបាល និងអង្គការអន្តរជាតិនានា ដែលបានមកទស្សនា បំពេញភារកិច្ច រស់នៅ និងបំពេញបេសកកម្មនៅក្នុងព្រះរាជាណាចក្រកម្ពុជា ជាពិសេស ការបំរើ និងការធានាដល់កិច្ចប្រជុំថ្នាក់ជាតិ តំបន់ និងអន្តរជាតិធំៗ ដែលព្រះរាជាណាចក្រកម្ពុជាមានកិត្តិយសបានរៀបចំកន្លងមកនៅរាជធានីភ្នំពេញ និងនៅខេត្តសៀមរាប។ លទ្ធផលជាវិជ្ជមាននេះ បានទទួលការកោតសរសើរ និងជំនឿទុកចិត្តថែមទៀត ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ មកលើការដឹកនាំរបស់រាជរដ្ឋាភិបាល។

ជាមួយនេះដែរ រាជរដ្ឋាភិបាល រួមជាមួយប្រជាពលរដ្ឋខ្មែរ បានចូលរួមដោយក្តីសោមនស្សរីករាយ ក្នុងទិវាបុណ្យពិសាខបូជា ព្រះរាជពិធីបុណ្យច្រត់ព្រះនង្គ័ល ព្រះរាជពិធីបុណ្យចំរើនព្រះជន្មព្រះករុណា ព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា គំរប់ ៨១ ព្រះវស្សា យាងចូល ៨២ព្រះវស្សា ថ្ងៃទី ៣០-៣១ ខែ តុលា និងថ្ងៃទី ០១ ខែ វិច្ឆិកា ឆ្នាំ ២០០៣ ព្រះរាជពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ និងបណ្តែតប្រទីប ថ្ងៃទី ០៧-០៨ និងថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៣ ពិធីមិទ្ទិញព្យុហយាត្រាមហាជន នៃបុណ្យខួបឯករាជ្យជាតិលើកទី៥០ (០៩ វិច្ឆិកា ១៩៥៣-០៩ វិច្ឆិកា ២០០៣) ការប្រារព្ធទិវាបុណ្យចូលឆ្នាំសកល ២០០៤ ជាមួយប្រជាជនលើពិភពលោក និងការប្រារព្ធទិវាជ័យជំនះថ្ងៃ ០៧ មករា លើរបបប្រល័យពូជសាសន៍លើកទី២៥ ព្រមទាំងទិវាបុណ្យមាឃបូជា នាថ្ងៃ ១៥កើត ខែ មាឃ ត្រូវនឹងថ្ងៃទី ០៥ ខែ កុម្ភៈ ឆ្នាំ ២០០៤ ក្នុងស្ថានភាពដែលប្រជាជនកម្ពុជាបាន និងកំពុងទទួលបាននូវសន្តិភាពពេញលេញទូទាំងព្រះរាជាណាចក្រកម្ពុជា ។

- **សម្តេចព្រះសង្ឃរាជទាំងពីរគណៈ ព្រះថេរានុត្ថេរៈ គ្រប់ព្រះអង្គជាទីសក្ការៈ**
- **សម្តេច ព្រះអង្គម្ចាស់ អ្នកអង្គម្ចាស់ ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី**
- **បងប្អូនជនរួមជាតិ ដែលកំពុងរស់នៅក្នុង និងក្រៅព្រះរាជាណាចក្រកម្ពុជាទាំងអស់ជាទីមេត្រី**

កិច្ចដំណើរការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រនីតិកាលទី៣ ដែលបានរៀបចំធ្វើឡើង កាលពីថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៣ បានប្រព្រឹត្តទៅក្នុងលក្ខណៈសេរី ត្រឹមត្រូវ យុត្តិធម៌ និងគ្មានអំពើហិង្សា។ ទាំងកិច្ចដំណើរការរៀបចំ និងលទ្ធផលនៃការបោះឆ្នោត ត្រូវបានទទួលស្គាល់ពីមជ្ឈដ្ឋានជាតិ និងអន្តរជាតិ ដែលបង្ហាញអោយឃើញថា ការអនុវត្តលទ្ធិប្រជាធិបតេយ្យសេរីពហុបក្សនៅព្រះរាជាណាចក្រកម្ពុជា បាន និងកំពុងចាក់ឫសយ៉ាងជ្រៅក្នុងស្រទាប់ប្រជាពលរដ្ឋខ្មែរយើងទាំងមូល ។

ទោះបីរហូតមកដល់បច្ចុប្បន្ន រាជរដ្ឋាភិបាលថ្មីពុំទាន់ត្រូវបានបង្កើតឡើងក្តី ក៏រាជរដ្ឋាភិបាលបច្ចុប្បន្ន បាន និងកំពុងបន្តការងាររបស់ខ្លួនស្របតាមស្មារតីនៃរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី និងលិខិតបទដ្ឋានគតិយុត្តិជាធរមាននានា ដើម្បីធានាអោយខាងតែបាននូវនិរន្តរភាពនៃកិច្ចការរដ្ឋ ប្រក្រតីភាព និងស្ថិរភាពនៃជីវភាពសង្គម និងមិនមានឧបសគ្គណាមួយដល់ដំណើរការសកម្មភាពប្រចាំថ្ងៃរបស់រាជរដ្ឋាភិបាល ក៏ដូចជាការអភិវឌ្ឍមាតុភូមិអង្គរនៃយើងឡើយ ។

ជាមួយនេះ គណបក្សដែលទទួលបានសម្លេងគាំទ្រពីប្រជាពលរដ្ឋម្ចាស់ឆ្នោត បាន និងកំពុងខិតខំយ៉ាងសកម្មក្នុងការចរចា ដើម្បីដោះស្រាយទំលុះទំលាយភាពទ័លច្រកខាងនយោបាយ សំដៅឈានទៅបង្កើតរាជរដ្ឋាភិបាលចំរុះថ្មីមួយ ស្របតាមបំណងប្រាថ្នារបស់ប្រជាពលរដ្ឋទូទាំងព្រះរាជាណាចក្រកម្ពុជា ។

ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាល បាន និងកំពុងអនុវត្តនូវភារកិច្ចបួនយ៉ាងគឺ ទី១ : ការរក្សាអោយបាននូវស្ថិរភាពនយោបាយ សន្តិសុខ សុវត្ថិភាព សណ្តាប់ធ្នាប់សាធារណៈ ដើម្បីបំរើជីវភាពរស់នៅដ៏សុខសាន្ត និងប្រក្រតីរបស់ប្រជាពលរដ្ឋ ។ ទី២ : ការរក្សានូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ទប់ស្កាត់អតិផរណា និងជំរុញកំណើនសេដ្ឋកិច្ចបន្តទៀត ។ ឆ្នាំនេះប្រជាពលរដ្ឋកម្ពុជា នៅស្ទើរទូទាំងប្រទេសមានសេចក្តីរីករាយក្រៃលែង ដោយទទួល

ផលស្រូវល្អបំផុត ដែលមិនធ្លាប់មានតាំងពីថ្ងៃរំដោះ ៧មករា ឆ្នាំ ១៩៧៩មក ។ ទី៣ : ធានាបន្តទៀតនូវនិរន្តរភាពរបស់រដ្ឋ និងរបស់កិច្ចការរដ្ឋនៅគ្រប់ផ្នែកនៃការគ្រប់គ្រង និងដឹកនាំប្រទេសជាតិ បន្តជំរុញអនុវត្តអោយកាន់តែទូលំទូលាយ និងស៊ីជំរៅថែមទៀត នូវគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ ពិសេសកម្មវិធីកំណែទំរង់សំខាន់ៗទាំងឡាយ ដែលបាន និងកំពុងដំណើរការដោយមិនរង់ចាំការបង្កើតរដ្ឋាភិបាលថ្មី និង ទី៤ : ការបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងទំនាក់ទំនងល្អជាមួយសហគមន៍អ្នកផ្តល់ជំនួយ និងបណ្តាប្រទេសជាមិត្តទាំងអស់ ដើម្បីទទួលជាបន្តនូវជំនួយសំរាប់អភិវឌ្ឍន៍ប្រទេសយើង ។

ទាំងនេះ សុទ្ធសឹងជាគន្លឹះដ៏សំខាន់បំផុត សំរាប់ធានាការអភិវឌ្ឍប្រកបដោយចីរភាព សំដៅកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ហើយផ្តល់ជូនប្រទេសជាតិ និងប្រជាជនគ្រប់ស្រទាប់ជាន់ថ្នាក់ នូវវឌ្ឍនភាព វិបុលភាព ភាពសុខដុមរមនា និងជីវភាពរស់នៅសមរម្យថ្លៃថ្នូរ ។

ឆ្នាំចាស់បានកន្លងផុតទៅ ក៏ប៉ុន្តែបានបន្សល់ទុកនូវសមិទ្ធផលធំៗជាច្រើន ដែលរាជរដ្ឋាភិបាលសំរេចបាន ហើយដែលអាចចាត់ទុកជាបទពិសោធន៍ដ៏មានតំលៃសំរាប់យកទៅអនុវត្តភារកិច្ចបន្ត និងដោះស្រាយបញ្ហាប្រឈមជាច្រើនទៀតនៅក្នុងឆ្នាំថ្មី ។

ក្នុងឱកាសដ៏មហានក្ខត្តឫក្សនេះ ក្នុងនាមរាជរដ្ឋាភិបាល និងក្នុងនាមខ្ញុំព្រះករុណាខ្ញុំ សូមថ្វាយ និងប្រគេនពរចំពោះសម្តេចព្រះសង្ឃរាជទាំងពីរគណៈ និងព្រះសង្ឃគ្រប់ព្រះអង្គ និងសូមជូនពរដល់ជនរួមជាតិខ្មែរ ដែលកំពុងរស់នៅក្នុង និងក្រៅប្រទេស មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងនគរបាលជាតិ ក្មួយៗសិស្សានុសិស្ស និស្សិត យុវជន យុវនារី កម្មករ និយោជិត សង្គមស៊ីវិល ធុរជន និងវិនិយោគិន ដែលកំពុងស្នាក់នៅលើទឹកដី នៃព្រះរាជាណាចក្រកម្ពុជា និងនៅឯបរទេស សូមទទួលបាននូវសិរីសួស្តី ជ័យមង្គល និងវិបុលសុខគ្រប់ប្រការកុំបីឃ្លៀងឃ្លាតឡើយ ចាប់តាំងពីពេលចូលឆ្នាំថ្មី នេះតរៀងទៅ ។

សូមទេវតាឆ្នាំថ្មី ព្រះនាម **រាក្សសាទេវី** តាមជួយបីបាច់ថែរក្សាគាំពារ និងជាប្រទីបបំភ្លឺផ្លូវដល់ប្រជាពលរដ្ឋខ្មែរ មន្ត្រីរាជការ កងយោធពលខេមរភូមិន្ទ កងរាជអាវុធហត្ថ កងនគរបាលជាតិ ក្មួយៗសិស្សានុសិស្ស និស្សិត យុវជន យុវនារី កម្មករ និយោជិត សង្គមស៊ីវិល ធុរជន និងវិនិយោគិនទាំងអស់ អោយប្រកាន់ខ្ជាប់នូវព្រហ្មវិហារធម៌ទាំងបួន គឺ មេត្តា ករុណា មុទិតា និងឧបេក្ខា ចៀសវាងអោយផុតនូវអំពើហិង្សានានា ទាំងនៅក្នុងសង្គមជាតិ និងក្នុងគ្រួសារ ព្រមទាំងខិតខំពង្រឹងសាមគ្គីភាព ឯកភាពជាតិ ឧស្សាហ៍ព្យាយាម ក្នុងការងារ និងរៀនសូត្រ ដើម្បីជំរុញកិច្ចអភិវឌ្ឍន៍ធនធានមនុស្ស សំរាប់កែលំអជីវភាពក្នុងគ្រួសារ ក៏ដូចជារួមចំណែកក្នុងការអភិវឌ្ឍវិស័យសេដ្ឋកិច្ច សង្គមកិច្ច អោយមានសន្ទុះកាន់តែឈានឡើងជាលំដាប់ សំដៅធ្វើអោយប្រជាពលរដ្ឋខ្មែរទូទាំងព្រះរាជាណាចក្រកម្ពុជា បានចាកផុតពីភាពក្រីក្រ ក្នុងពេលអនាគតដ៏ខ្លីខាងមុខនេះ ។

សូមអរព្រះគុណ និងអរគុណ

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ២០០៤

នាយករដ្ឋមន្ត្រី

ហ៊ុន សែន